# របាយការណ៍សង្ខេប

# ស្តីពី

# វឌ្ឍនភាព និងទិសដៅការងាររបស់សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ

# ដោយលោក លឹម ឌី ចៅសង្កាត់ដងទង់

- ជាបឋម សូមគោរពឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ជាទីគោរព !
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់នៃអង្គពិធីទាំងមូលជាទីគោរពស្នេហា !
- ថ្ងៃនេះ ជាថ្ងៃដ៏មហាកិត្តិយសរបស់ខ្ញុំបាទ ដែលឯកឧត្តមប្រធានបានផ្តល់ឱកាសដល់រូបខ្ញុំចូលរួមជាវាគ្មិន នៃសន្និសិទសារព័ត៌មានក្រោមប្រធានបទ “វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅបន្តរបស់រដ្ឋបាលខេត្តកោះកុង”

មុននឹងឈានចូលដល់របាយការណ៍វឌ្ឍនភាព នៃសង្កាត់ដងទង់

ខ្ញុំបាទសូម **អរគុណសន្តិភាព និងសូមអរគុណនយោបាយឈ្នះ ឈ្នះ**

ខ្ញុំបាទសូមអនុញ្ញាតិជម្រាបជូននូវរបាយការណ៍វឌ្ឍនភាពសង្ខេបរបស់រដ្ឋបាលសង្កាត់ដងទង់ នៃក្រុងខេរមភូមិន្ទ ខេត្តកោះកុង ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម ៖

**I- ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ**

សង្កាត់ដងទង់ជាសង្កាត់មួយ ស្ថិតក្នុងចំណោមសង្កាត់ទាំងបីនៃក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលមានព្រំប្រទល់ ខាងកើត ខាងត្បូងជាប់នឹងសង្កាត់ស្ទឹងវែង ខាងលិចជាប់នឹងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ខាងជើងជាប់នឹងសង្កាត់ស្មាច់មានជ័យ មានផ្ទៃដីសរុបចំនួន ៣,០៧០ហិកតា ។ មានហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុង និងផ្លូវក្រាលកៅស៊ូអាសេ សំខាន់ៗប្រវែងសរុប ៣,០៨៩ ម៉ែត្រ ដែលតភ្ជាប់កាត់ព្រំប្រទល់សង្កាត់ដងទង់ សង្កាត់ស្មាច់មានជ័យ និងសង្កាត់ស្ទឹងវែង។

រដ្ឋបាលដែនដី បានចែកចេញជា ៤ភូមិ គឺ ភូមិ១ ភូមិ២ ភូមិ៣និងភូមិ៤ ស្ថិតិគ្រួសារនៅក្នុងសង្កាត់សម្រាប់ឆ្នាំ២០២១ មានចំនួន ២,៦៦៧ គ្រួសារ ប្រជាពលរដ្ឋសរុប ១៣,៨៩៥នាក់ ក្នុងនោះស្រីចំនួន ៦,៩៥០នាក់។ ក្នុងនោះស្ត្រីជាមេគ្រួសារទូទាំងសង្កាត់ មានចំនួន ១,១១៨នាក់ ស្មើនឹង១៦ភាគរយ នៃចំនួនប្រជាពលរដ្ឋសរុប។ប្រជាពលរដ្ឋ អាយុ១៨ឆ្នាំឡើង មានចំនួន ៨,១០៩នាក់ ស្រី៤,០៩៩ នាក់។

ប្រជាពលរដ្ឋមានមុខរបរផ្សេងៗគ្នា ភាគច្រើនជាអាជីវករលក់ដូរគ្រប់ប្រភេទប្រមាណ ៣៨,៥% អ្នកប្រកបរបរនេសាទ២៦,២ % អ្នកចិញ្ចឹមសត្វ និងដំណាំរួមផ្សំ ៣,៦ % អ្នកមានមុខរបរសិប្បកម្មជាចំបង

ការផលិតពីដែកអាលុយមីញ៉ូម និងផលិតកម្មផ្សេងៗ ១,១ % មុខរបរសេវាកម្មចំនួន ៤% ជាមន្ត្រីរាជការមានចំនួន ៩% និងកម្មករ កម្មការីនី ចំនួន១៧,៦%។

**II- ផ្នែកសេដ្ឋកិច្ច**

ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់សង្កាត់ដងទង់ ក្នុងអាណត្តិមុន និងប៉ុន្មានឆ្នាំចុងក្រោយ ក៏ដូចជាបច្ចុប្បន្ននេះ មានហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់ខ្វាត់ខ្វែងគ្រប់ភូមិ ដែលបានប្រែក្លាយពីផ្លូវក្រាលដីក្រួសក្រហមទៅជាផ្លូវបេតុង និងផ្លូវក្រាលកៅស៊ូអាសេ ការរៀបចំផ្សារសម្រាប់ដោះដូរទំនិញគ្រប់ប្រភេទ ការលើកកម្ពស់សេដ្ឋកិច្ចជូនប្រជាពលរដ្ឋ ដោយក្នុងសង្កាត់យើងមានផ្សារចំនួនពីរ មួយគឺផ្សារដងទង់ និងមួយទៀតគឺផ្សារភូមិ៤ ដែលជាផ្សារទើបនឹងបង្កើតថ្មីក្នុងឆ្នាំ២០២០ ក្រោមការផ្តួចផ្តើមរបស់**លោកជំទាវ មិថុនា ភូថង** អភិបាល នៃគណៈអភិបាលខេត្តកោះកុង។

កាលពីអាណត្តិទី៣ សង្កាត់ដងទង់មានផ្លូវបេតុងអាមេសរុប ៥,០៨៨ម៉ែត្រ រហូតដល់អាណត្តិទី៤ ក្នុងឆ្នាំ២០២០ រដ្ឋបាលសង្កាត់ដងទង់បានខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដូចខាងក្រោម ៖

- បានសាងសង់ផ្លូវបេតុងអាមេ ទូទាំងសង្កាត់បានប្រវែងសរុប ៣,៣៨២ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៩៥២,៥៨៧,៤៦៩រៀល ដែលជាមូលនិធិប្រចាំឆ្នាំរបស់សង្កាត់។
- បានដាក់លូមូលដោះទឹក១កន្លែង ប្រវែង៨៣ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៥៨,៥១៥,៩០០ រៀល ដែលជាមូលនិធិសង្កាត់។
- បានស្តារប្រឡាយ ១កន្លែង ប្រវែង ៣៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៣,៥០០,០០០រៀល ដែលជាមូលនិធិសង្កាត់។
- បានជួសជុលអគាររដ្ឋបាលសង្កាត់ ចំណាយថវិកាអស់ចំនួន ៣៥,០០០,០០០រៀល ដែលជាមូលនិធិសង្កាត់។ ជាមួយគ្នានោះដែរ រដ្ឋបាលដងទង់ បានខិតខំកៀគរសប្បុរជនជាតិ អន្តរជាតិ មន្ទីរអង្គភាពផ្សេងៗទៀត តាមរយៈសមាហរណកម្មផែនការថ្នាក់ក្រុង សង្កាត់ ដើម្បីជួយសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាការលើកកម្ពស់កំរិតជីវភាពរបស់ប្រជាជនបានមួយកំរិតហើយជាលទ្ធផលមានដូចខាងក្រោម ៖
- ផ្លូវក្រាលកៅស៊ូអាសេ ប្រវែងសរុប ២,៥១៤ម៉ែត្រ និងលូមូលដោះទឹកប្រវែងសរុប ១,១០២ម៉ែត្រ និងស្តារលូប្រវែងសរុប ៩៤៥ម៉ែត្រ អនុវត្តដោយរដ្ឋបាលខេត្តកោះកុង។
- ផ្លូវបេតុងអាមេប្រវែងសរុប ៦៩៧ម៉ែត្រ អនុវត្តដោយរដ្ឋបាលក្រុងខេមរភូមិន្ទ បើគិតដល់បច្ចុប្បន្នបេតុងអាមេ ទាំងអស់នោះ បានសាងសង់សម្រេចបាន ៨០ភាគរយហើយ។

**III- ផ្នែកសង្គមកិច្ច**

ផ្នែកសង្គមកិច្ច ជាផ្នែកមួយសំខាន់ ដែលលើកយកបញ្ហាសមភាពយេនឌ័រ មកបញ្ជ្រៀបចូលគ្រប់សកម្មភាពទាំងអស់ ក្នុងមូលដ្ឋាន ហើយកំពង់បានដោះស្រាយលើគ្រប់វិស័យ ជាពិសេសក្នុងវិស័យសេវាកម្មកសិកម្ម សុខាភិបាល និងវិស័យអប់រំ ។ ក្រុមប្រឹក្សាសង្កាត់ និងបន្តដោះស្រាយបញ្ហាជាច្រើន នៃការបញ្ជ្រៀបយេនឌ័រ នៃគ្រប់ទិដ្ឋភាពទាំងអស់ នៃអភិបាលកិច្ចសង្គម។

បញ្ហាដ៏សំខាន់មួយទៀត គឺត្រូវបង្កើតឲ្យមានតុល្យភាពយេនឌ័រ ដែលប្រកបដោយសមធ៌ម និងមានស្ថិរភាព(រវាងបុរស និងស្ត្រី រវាងក្មេងប្រុស និងក្មេងស្រី)ក្នុងការទទួលបាននូវទំនិញ សេវាកម្មនានា ការអប់រំ និងសេវាថែទាំសុខភាព ។

ការអប់រំ វាជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍន៍ ធនធានមនុស្សនៅក្នុងសង្កាត់ សម្រាប់ការវិនិយោគទៅថ្ងៃអនាគត់។ ប៉ុន្តែស្ថានភាពអប់រំនៅក្នុងសង្កាត់មិនទាន់បានល្អប្រសើរនៅឡើយ ដោយសារនៅក្នុងសង្កាត់ ខ្វះសាលាមត្តេយ្យរដ្ឋ និងមានសាលាមត្តេយ្យឯកជន ចំនួន ០៤កន្លែង ស្មើនឹង១៥បន្ទប់ ត្រូវនឹង១៥ថ្នាក់ មានសិស្សចំនួន ៦២៥នាក់ ស្រី ២៧៨នាក់  ចំនួនគ្រូបង្រៀនមាន ២០នាក់  ស្រី០២នាក់។ មានសាលាបឋមសិក្សារដ្ឋ ១កន្លែង ស្មើនឹង១០បន្ទប់ ត្រូវនឹង១៨ថ្នាក់ មានគ្រូបង្រៀន២៤នាក់ ស្រី ៦នាក់ សិស្សចំនួន ៤២៣នាក់ ស្រី២០២នាក់។មានសាលាបឋមសិក្សាឯកជន ចំនួន ៦កន្លែង ស្មើនឹង៣៤បន្ទប់ ត្រូវនឹង ៤០ថ្នាក់ មានគ្រូបង្រៀនចំនួន ៥៨នាក់ ស្រី៤៤នាក់ សិស្សចំនួន ១,៤០០នាក់ ស្រី ៧៣២នាក់។

មានអនុវិទ្យាល័យរដ្ឋចំនួន ០១កន្លែង ស្មើនឹង ១១បន្ទប់ មាន ០៣ថ្នាក់  មានសិស្សចំនួន ៩៥នាក់ ស្រី៥៧នាក់ មានគ្រូបង្រៀនចំនួន ១៤នាក់ ស្រី ០៤នាក់។ មានអនុវិទ្យាល័យឯកជន ចំនួន ០៣កន្លែង ស្មើនឹង ២២បន្ទប់ មាន១១ថ្នាក់ មានសិស្ស ៤៥៦នាក់ ស្រី ២០៣នាក់ មានគ្រូបង្រៀនចំនួន ១៤នាក់។

មានវិទ្យាល័យឯកជន ចំនួន ០១កន្លែង ស្មើនឹង០១បន្ទប់ មាន០១ថ្នាក់ សិស្សមាន២១នាក់ ស្រី១០នាក់ មានគ្រូបង្រៀនចំនួន ០៦នាក់ ស្រី០២នាក់។

ដើម្បីអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងសង្កាត់  ក្រុមប្រឹក្សាសង្កាត់  បានបង្កើនកិច្ចសហការជាមួយ  មេភូមិ នាយកសាលា គ្រូបង្រៀន និងមាតា បិតា អាណាព្យាបាលសិស្ស  និងជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ដើម្បីពិគ្រោះរិះរកគ្រប់មធ្យោបាយ  ក្នុងការជំរុញឲ្យកុមារទាំងអស់  ទៅរៀនជាប្រចាំឲ្យបានយ៉ាងហោចណាស់ចប់កំរិតអនុវិទ្យាល័យ  ដោយសង្កាត់លើកគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិល  និងត្រៀមបើកវគ្គផ្សព្វផ្សាយ ដូចខាងក្រោម ៖

- ការផ្សព្វផ្សាយអំពីសុខភាពមាតា  និងទារកបានចំនួន២៧វគ្គ  ចំណាយអស់ថវិកាមូលនិធិរបស់សង្កាត់ចំនួន ២,៤៨៤,០០០រៀល។
- ការគាំទ្រការធ្វើដំណើរសម្រាប់សំរាលកូននៅមណ្ឌលសុខភាព បានចំនួន៥៤នាក់ ចំណាយថវិកាមូលនិធិសង្កាត់ចំនួន ២១៦,០០០ រៀល។
- ការផ្តល់អាហារូបត្ថម្ភដល់ស្ត្រីក្នុងអំឡុងពេលសំរាលកូននៅមណ្ឌលសុខភាពបានចំនួន  ៥៤នាក់ ចំណាយថវិកាចំនួន ២,១៦០,០០០រៀល។
- ផ្តល់កិច្ចដំណើរការមត្តេយ្យសិក្សាសហគមន៍បានចំនួន ០១ឆ្នាំ ចំណាយថវិកាមូលនិធិសង្កាត់អស់ចំនួន ១,២០០,០០០រៀល។
- ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ បានចំនួន ៥៤គ្រួសារ ចំណាយថវិកាមូលនិធិសង្កាត់ ចំនួន ៩,១៨០,០០០រៀល។

- ផ្តល់ធុងចម្រោះទឹកស្អាត បានចំនួន ៧២គ្រួសារ ចំណាយថវិកាចំនួន ៧,២០០, ០០០រៀល ដែលជាមូលនិធិសង្កាត់។
- ការប្រជុំរបស់ គ.ក.ន.ក បានចំនួន ១០៨លើក ចំណាយថវិកាចំនួន ៨,៦៤០,០០០រៀល ដែលជាមូលនិធិសង្កាត់។
- ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធ និងកិច្ចការពារកុមារ ក្នុងចំណោមកុមារងាយរងគ្រោះបំផុត(ផ្តល់សំលៀកបំពាក់ និងសម្ភារៈសិក្សា) បានចំនួន ១៨០នាក់ ចំណាយថវិកាចំនួន ៧,២០០,០០០រៀល ជាមូលនិធិសង្កាត់ ។
- ការអប់រំ និងលុបបំបាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន ៧,២០០,០០០រៀល ជាមូលនិធិសង្កាត់។
- អប់រំយុវជន យុវនារី អំពីសុខភាពបន្តពូជ និងការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន ៧,២០០,០០០រៀល ដែលជាមូលនិធិសង្កាត់។
- គាំទ្រការធ្វើដំណើរដឹលជនរងគ្រោះទៅកាន់សេវាសង្គ្រោះ បានចំនួន ១៨នាក់ ចំណាយថវិកាចំនួន ៧២០,០០០រៀល ជាមូលនិធិសង្កាត់។
- អប់រំ និងលុបបំបាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ បានចំនួន ១៨វគ្គ ចំណាយថវិកាចំនួន១,៦៥៦,០០០រៀល ជាមូលនិធិសង្កាត់។
- បានផ្សព្វផ្សាយអំពីការទប់ស្កាត់ការឆ្លងជម្ងឺកូវីដ១៩ បានចំនួន ៧២លើក នៅទូទាំងសង្កាត់។

**យ៉ាងណាមិញក្រៅពីការអនុវត្តមូលនិធិរបស់សង្កាត់ នៅមានសកម្មភាពរបស់មន្ទីរអង្គភាពមួយចំនួន ដែលបានអនុត្តន៍ដូចខាងក្រោម ៖**

- ការអប់រំស្ត្រីឲ្យមកសំរាលកូននៅមណ្ឌលសុខភាព មន្ទីរពេទ្យ បានចំនួន០៦លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយអំពីសុខភាពបន្តពូជ និងព្យាបាលជម្ងឺកាមរោគបានចំនួន ០៤លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយដល់ស្ត្រីឲ្យមកពិនិត្យផ្ទៃពោះ ៤ដងយ៉ាងតិច បានចំនួន ០៤លើក អនុវត្តដោយ មន្ទីរសុខភិបាលខេត្ត។
- អប់រំស្ត្រី ក្នុងការជំរុញដៃគូរឲ្យពិនិត្យឈាមរកមេរោគអេដស៍ បានចំនួន ០៤លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។
- ផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃការប្រើស្រោមអនាម័យនិងការ ការពារឲ្យបានត្រឹមត្រូវពីជម្ងឺកាមរោគ បានចំនួន ០៤លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។

- ចុះដាក់ថ្នាំអាបែតតាមភូមិ បានចំនួន ០១លើក អនុវត្តដោយមន្ទីរសុខភិបាលខេត្ត។

IV- **ផ្នែកធនធានធម្មជាតិ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- បានចូលរួមវគ្គបណ្តុះបណ្តាល អំពីការបង្ការគ្រោះធម្មជាតិ ចំនួន ០៤វគ្គ
- បានចូលរួមធ្វើអនាម័យជាសាធារណៈ ក្នុងការលើកកម្ពស់បរិស្ថាន ចំនួន ១៨លើក
- បានចូលរួមផ្សព្វផ្សាយអំពីការថែទាំ ការបង្ការ និងការអភិរក្ស ធនធានសមុទ្រ ចំនួន ០៤លើក
- បានចូលរួមចែកអំណោយផ្សេងៗ ជាមួយសាខាកាកបាទក្រហមខេត្ត ក្រុងដល់គ្រួសាររងគ្រោះដោយខ្យល់ព្យុះតន្ត្រាក់ ចំនួន ១១លើក ស្មើ ៧២គ្រួសារ។
- បានចូលរួមចែកទឹកជាមួយខេត្ត ក្រុង ដល់ប្រជាពលរដ្ឋខ្វះខាតទឹកស្អាតប្រើប្រាស់នៅរដូវប្រាំង បានចំនួន ១,៤៧០គ្រួសារ។
- បានចូលរួមវគ្គផ្សព្វផ្សាយស្តីពីការអភិរក្សត្រីកាម៉ុង ចំនួន ០២លើក
- បានចូលរួមផ្សព្វផ្សាយ ការធ្វើអនាម័យដល់ប្រជាជនតាមគេហដ្ឋាន ដើម្បីឲ្យចេះញែកសំរាមសំណល់រឹង រាវ បានចំនួន ២៨លើក។

V- **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

**១- អំពីរចនាសម្ព័ន្ធក្រុមប្រឹក្សា បុគ្គលិក ការចេញដីកា សេចក្តីសម្រេច និងសេវាសាធារណៈ**

- ក្រុមប្រឹក្សាសង្កាត់ មានចំនួន ១១នាក់ ស្រី ០៣នាក់
- ចៅសង្កាត់ ចំនួន ០១នាក់ (ប្រុស)
- ចៅសង្កាត់រង ចំនួន ០២នាក់ ប្រុស០១ ស្រី ០១នាក់
- ស្មៀនសង្កាត់ ចំនួន ០១នាក់ (ប្រុស)
- មេភូមិ ចំនួន ០៤នាក់ (ប្រុស)
- អនុភូមិ ចំនួន ០៤នាក់ (ប្រុស)
- សមាជិកភូមិ ចំនួន ០៤នាក់ (ស្រី)
- ដីកា ដែលបានដាក់ចេញ ចំនួន ០៣ច្បាប់
- សេចក្តីសម្រេច ដែលបានដាក់ចេញ ចំនួន ៣២ច្បាប់
- លិខិតរដ្ឋបាលផ្សេងៗ ដែលបានដាក់ចេញ ចំនួន ១,៦២៣ច្បាប់
- លិខិតដែលបានទទួល ចំនួន ៨,៨៦១ច្បាប់
- ផ្តល់កាតរឹង ដើម្បីបើកប្រាក់ឧបត្ថម្ភដល់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និងការផ្តល់ប័ណ្ណសមធ៌ម ក្នុងឆ្នាំ២០២០ ដូចខាងក្រោម ៖

១- ផ្តល់កាតរឹង ដល់ស្ត្រីមានផ្ទៃចំនួន ៤១នាក់

២- ផ្តល់កាតរឹង ដល់កុមារអាយុក្រោម២ឆ្នាំចំនួន ៣៩នាក់

៣- ផ្តល់ប័ណ្ណសមធម៌តាមការស្នើសុំឆ្នាំ២០២០ ជូនដល់ប្រជាពលរដ្ឋ ចំនួន៦០៧នាក់

៤- បានផ្ទៀងផ្ទាត់ប័ណ្ណសមធម៌ (ប័ណ្ណ២០១៩-២០២០) ដើម្បីបើកប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលជូនប្រជាពលរដ្ឋក្នុងអំឡុងពេល កូវីដ ១៩ បានចំនួន ៩០៦នាក់។

**២- ការអនុវត្តមុខងារជាភ្នាក់ងារ**

**ក- ការងារអត្រានុកូលដ្ឋាន ឆ្នាំ២០២០**

- ចុះសំបុត្រកំណើត បានចំនួន ២៧៤នាក់ ស្រី ១៧៥នាក់
- ចុះសំបុត្របញ្ជាក់កំណើត បានចំនួន ២៨០នាក់ ស្រី ១៣៤នាក់
- ចេញសេចក្តីចម្លងសំបុត្រកំណើតបានចំនួន ៣២នាក់ ស្រី ១៥នាក់
- ចេញសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតបានចំនួន ២៤នាក់ ស្រី១៤នាក់
- ចុះសំបុត្រអាពាហ៍ពិពាហ៍ បានចំនួន ៦១គូ
- ចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បានចំនួន ២០គូ
- ចុះសំបុត្រមរណភាព បានចំនួន ៣៧នាក់ ស្រី ១៤នាក់
- ចេញសេចក្តីចម្លងសំបុត្រមរណភាព បានចំនួន ១៣នាក់ ស្រី ០៥នាក់

**ខ- ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ**

- ប្រជាពលរដ្ឋបានចុះឈ្មោះថ្មីក្នុងឆ្នាំ២០២០ ចំនួន ១៧៩នាក់ ស្រី ៨០នាក់
- ប្រជាពលរដ្ឋ ដែលត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ឆ្នាំ២០២០ ចំនួន ១៩០នាក់ ស្រី ៩៤នាក់។
- ប្រជាពលរដ្ឋសរុប ដែលមានឈ្មោះបោះឆ្នោត(ចាស់ និងថ្មី) មានចំនួន៧,៨៩៣ នាក់ ស្រី ៤,១៥៣នាក់។

**៣- កិច្ចសហប្រតិបត្តិការ និងសុខដុមនីយកម្ម ក្នុងសង្គម**

- បានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយក្រុមប្រឹក្សាសង្កាត់ ក្នុងការផ្តល់សេវាសាធារណៈ ការផ្តល់ផលប្រយោជន៍នានា ពីការអភិវឌ្ឍន៍ និងការផ្តល់កិច្ចគាំពារផ្នែកសង្គម ប្រកបដោយសមធម៌ ដល់គ្រប់ក្រុមប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- បានខិតខំលើកកម្ពស់ការផ្សព្វផ្សាយ និងការអប់រំប្រជាពលរដ្ឋ អំពីផលប្រយោជន៍នៃការរួបរួម និងការរស់នៅប្រកបដោយសុខដុមរមនា ជាមួយគ្នា។
- បានពង្រឹងសុខដុមនីយកម្មជំនឿ និងសាសនាផ្សេងៗគ្នានៅមូលដ្ឋាន ដើម្បីលើកកម្ពស់តំលៃសីលធម៌សង្គម និងគ្រួសារ។

- បានគាំទ្រ និងលើកទឹកចិត្ត ដល់ការបង្កើត និងដំណើរការសហគមន៍នៅមូលដ្ឋាន ព្រមទាំងគាំទ្រដល់សកម្មភាពនានា របស់អង្គការសង្គមស៊ីវិល និងផ្នែកឯកជននានា ដែលប្រតិបត្តិការដើម្បីបំរើការផ្តល់សេវា និងអភិវឌ្ឍនៅក្នុងសង្កាត់។

**៤- ការងារសន្តិសុខសណ្តាប់ធ្នាប់ និងការដោះស្រាយវិវាទ**

- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយ សង្កាត់ បានចំនួន ៨៧ករណី
- បានចូលរួមវគ្គផ្សព្វផ្សាយ អំពីចលនាប្រឡងប្រណាំងភូមិ ឃុំ មានសុវត្ថិភាព បានចំនួន១៨លើក។
- បានពង្រឹងការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ
- បានបំផុស និងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមក្នុងចលនាប្រជាការពារដើម្បីរក្សាសន្តិសុខ សុវត្ថិភាព ក្នុងភូមិ សង្កាត់។

ដើម្បីឲ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់ក្នុងការបង្ការទប់ស្កាត់ និងលុបបំបាត់ បទល្មើសនានា រដ្ឋបាលសង្កាត់ បានជំរុញអនុវត្តគោនយោបាយភូមិ សង្កាត់ មានសុវត្ថិភាពអោយសម្រេច បាននូវសំណូមពរទាំង០៩ចំណុច ដូចខាងក្រោម ៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និង ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើរហិង្សាក្នុងគ្រួសារ
- គ្មានក្រុមជនទំនើង ក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ បទល្មើសគ្រប់ប្រភេទ។
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព។
- គ្មានការត្រួតពិនិត្យខុសច្បាប់

កំលាំងប្រជាកាពារ ដែលបែងចែកដោយក្រុមប្រឹក្សាសង្កាត់ និងយាមតាមគោលដៅកំណត់រាងៗខ្លួនតាមភូមិនីមួយៗ បានសហការជាមួយនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ ចុះល្បាតតាមមូលដ្ឋានជារៀងរាល់យប់ ។

VI- **បញ្ហាប្រឈម**

- នៅមានការបំពុលបរិស្ថាន ដោយសារការចោលសំរាមពាសវាលពាសកាល របស់ប្រជាពលរដ្ឋ ព្រោះខ្វះការយល់ដឹងអំពីការធ្វើអនាម័យ និងសេវាកម្មដឹកសំរាមរបស់ក្រុមហ៊ុន មិនទាន់ល្អប្រសើរ។
- នៅខ្វះប្រព័ន្ធលូបង្ហូរទឹក
- នៅមានក្មេងទំនើង និងការចរាចរណ៍គ្រឿងញៀន ក្នុងមូលដ្ឋាន
- នៅមានគ្រោះថ្នាក់ចរាចរណ៍តិចតួច ដែលបណ្តាលមកពីប្រជាជនយើងខ្លះ មិនទាន់គោរពច្បាប់ចរាចរណ៍មួយរយភាគរយ ជាពិសេសក្រុមយុវជន និងក្មេងទំនើង។

VII- **ទិសដៅការងារបន្ត**

ទោះបីប្រទេសយើង បានស្ថិតក្នុងដំណាក់កាលប្រយុទ្ធប្រឆាំង និងជម្ងឺកូវីត១៩ ឬការដកប្រព័ន្ធអនុគ្រោះ EBA យ៉ាងណាក្តី ក៏រដ្ឋាភិបាល ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដ៏ឆ្នើមបំផុត របស់កម្ពុជា ក៏នៅតែបន្តវិភាជថវិកាដល់ក្រសួង មន្ទីរ អង្គភាពថ្នាក់ក្រោមជាតិទាំងអស់ ជាពិសេសនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ដើម្បីបន្តការងារបើកផ្តល់ប្រាក់បៀវត្ស ការងារអភិវឌ្ឍន៍នានា ជាធម្មតា។ ជាក់ស្តែង ក្នុងឆ្នាំ២០២១នេះ រដ្ឋបាលសង្កាត់ជងទង់ បានទទួលនូវថវិកាវិភាជពីរដ្ឋាភិបាលចំនួន ៣១៩,០០០,០០០ រៀល ក្នុងនោះថវិកា ២០០,០០០,០០០រៀល សម្រាប់ដំណើការរដ្ឋបាល និងឧបត្ថម្ភដល់ក្រុមប្រឹក្សា និងមន្ត្រីភូមិ ឯថវិកាចំនួន ១១៩,០០០,០០០រៀលទៀត សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន ដែលមានគម្រោង អតិភាពឆ្នាំ២០២១ ដូចខាងក្រោម ៖

- សាងសង់ផ្លូវបេតុងអាមេប្រវែង ៤៧៩ម៉ែត្រ ទទឹង ០៤ម៉ែត្រ
- ដាក់លូមូលដោះទឹកមួយកន្លែង ប្រវែង ០៥ម៉ែត្រ
- ធ្វើគម្របលូជ្រុង ប្រវែង ៣៥ម៉ែត្រ
- សម្រាប់ឆ្នាំបន្តបន្ទាប់ នៅតែបន្តកសាងជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលរួមមានបណ្តាញផ្លូវ ស្ពានគ្រប់ប្រភេទ មានការស្តារឡើងវិញអោយបានឆាប់រហ័ស នូវបណ្តាញផ្លូវលំដែលខូចខាតដោយទឹកជក់ក្នុងឆ្នាំកន្លងមកដើម្បីជានាការធ្វើដំណើរ និងដឹកជញ្ជូនរបស់ប្រជាជននៅតាមមូលដ្ឋានទៅកាន់ទីផ្សារ និងកន្លែងដទៃទៀតបានស្រួល និងឆាប់រហ័ស។
- ពង្រឹងការប្រើប្រាស់ផ្លូវ ប្រកបដោយប្រសិទ្ធិភាព ទប់ស្កាត់ការផ្ទុកលើសទំងន់របស់យានយន្តគ្រប់ប្រភេទ លើផ្លូវដែលគ្រប់គ្រងដោយសង្កាត់។
- ខិតខំបំផុសប្រជាជន សប្បុរសជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា

បន្តចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ និងគ្រប់គ្រងផ្លូវអោយកាន់តែមានលក្ខណៈល្អប្រសើរឡើង ពិសេសកែលំអរជាជំហ៊ានៗ នូវផ្លូវលំពីក្រាលគ្រួសក្រហមទៅជាផ្លូវក្រាលបេតុងអាមេ។

- ជំរុញការចូលរួមពីស័យឯកជន ក្នុងការអភិវឌ្ឍន៍ និងថែទាំផ្លូវថ្នល់ព្រមទាំងការផ្តល់សេវាកម្ម ដឹកជញ្ជូននៅក្នុងទីក្រុង ទីប្រជុំជន និងសង្កាត់។
- ជំរុញការផ្សព្វផ្សាយនូវច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានទូលំទូលាយដល់ប្រជាជន អំពីសុវត្ថិភាព នៃការដឹកជញ្ជូន និងពង្រឹងសុវត្ថិភាពចរាចរណ៍។
- ជំរុញការផ្សព្វផ្សាយការធ្វើអនាម័យ ដើម្បីធានាបាននូវសុខមាលភាពល្អ និងបរិស្ថានល្អ ក៏ដូចជាលើកកម្ពស់សោភ័ណ្ឌភាព និងទេសចរណ៍ផងដែរ។
- ធានាឲ្យប្រជាជននៅតាមភូមិនីមួយៗ មានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ក្នុងជីវភាពប្រចាំថ្ងៃ តាមរយៈការស្តារ ជីកអណ្តូងនិងការដោះស្រាយទឹកតាមមធ្យោបាយផ្សេងៗនៅភូមិដែលខ្វះទឹកប្រើប្រាស់។
- ជំរុញការផ្គត់ផ្គង់ទឹកស្អាត ដែលមានតំលៃសមរម្យ និងប្រើប្រាស់មានអនាម័យ និងផាសុកភាព អោយដល់សហគមន៍មូលដ្ឋាន។
- លើកទឹកចិត្តផ្នែកឯកជន ក្នុងការវិនិយោគលើវិស័យអគ្គីសនី សំដៅជំរុញការផ្គត់ផ្គង់អគ្គីសនី ដែលមានតំលៃសមរម្យ ផ្អែកលើការអភិវឌ្ឍន៍ ប្រភពថាមពល ដែលតភ្ជាប់ពីបណ្តាញជាតិដល់មូលដ្ឋានប្រើប្រាស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី** !

ខាងលើនេះ គឺជារបាយការណ៍សង្ខេប ស្តីពីលទ្ធផល និងសមិទ្ធផលនានា ដែលរដ្ឋបាលសង្កាត់ដងទង់សម្រេចបាន ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាសង្កាត់ដងទង់ ក្នុងអាណត្តិទី៤នេះ ហើយយើងខ្ញុំទាំងអស់គ្នា ក្នុងនាមតំណាងឲ្យប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជាការអនុវត្តមុខងារតំណាងរដ្ឋ សូមប្តេជ្ញាចិត្តបន្តការផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរ ឆាប់រហ័ស មានតម្លាភាព និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខដឹកនាំ និងបន្តការអភិវឌ្ឍន៍មូលដ្ឋានជានិច្ចនិរន្ត។

**សូមអរគុណសន្តិភាព**!

ជាទីបញ្ចប់ និងក្នុងឱកាសដ៏វិសេសវិសាលនេះ សូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា នៃអង្គពីធីទាំងមូល សូមទទួលបាននូវ ពុទ្ធពរទាំង៤ប្រការ គឺអាយុវណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!